JITCO

# とも

～ស្វែងយល់បន្ថែមអំពីប្រទេសជប៉ុន～

2026
1
លេខសម្រាប់រដូវរងា

## មកដឹងតាមរយៈតុក្កតា សុបិនដំបូង




នៅប្រទេសជប៉ុនគឺមានវប្បធម៌ទាយជោគវាសនាពេញមួយឆ្នាំដោយផ្អែកទៅលើ "សុបិនដំបូង"។ ឃ្លាថា "**一富士二鷹三茄子** (មួយភ្នំហ្វ៊ុជី ពីរសត្វស្ទាំង បីផ្លែត្រប់)" ដែលមានកំណើតឡើងតាំងពីសម័យអេដុ គឺជាឃ្លាដែលផ្គុំពាក្យដែលមានសម្លេងស្រដៀងគ្នា ដោយនៅក្នុងនោះ ភ្នំហ្វ៊ុជី(Fuji)គឺស្រដៀងនឹងពាក្យថា"សុវត្ថិភាព(Buji)"ឬ"មិនស្លាប់(Fushi)" ចំណែកសត្វស្ទាំង(Taka)គឺស្រដៀងនឹងពាក្យថា"ខ្ពង់ខ្ពស់(Takai)" រីឯផ្លែត្រប់(Nasu)គឺស្រដៀងនឹងពាក្យថា"ជោគជ័យ(Nasu)" ដូច្នេះ គេតែងនិយាយថាបើយល់សប្តិឃើញរបស់ទាំងនេះនៅក្នុងសុបិនដំបូង នោះគឺជាប្រផ្នូលដ៏ល្អ។


"Tomo" ត្រូវបានបោះពុម្ពផ្សាយជាភាសាជប៉ុនដែលភ្ជាប់ដោយសម្លេងអាន និង ជាភាសាចំនួន9ទៀត (វៀតណាម ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ ខ្មែរ មីយ៉ាន់ម៉ា ម៉ុងហ្គោលី និងអង់គ្លេស) ដើម្បីផ្តល់ព័ត៌មានដែលមានប្រយោជន៍សម្រាប់ការរស់នៅក្នុងប្រទេសជប៉ុននិងផ្តល់នូវគន្លឹះនានាសម្រាប់ការសិក្សាភាសាជប៉ុន។
（https://www.jitco.or.jp/ja/tomo/）



\ នៅពេលអាសន្ន /

# លេខ "110" និង លេខ "119"



លេខ "110" និង លេខ"119" គឺជាលេខទូរសព្ទដែលប្រើនៅពេលមានស្ថានភាពអាសន្នកើតឡើង។ លេខ "110" ដែលភ្ជាប់ទៅស្ថានីយប៉ូលិសគឺសម្រាប់ជូនដំណឹងនៅពេលកើតមានឧក្រិដ្ឋកម្ម ចោរកម្ម ឬ គ្រោះថ្នាក់ចរាចរណ៍ជាដើម។ លេខ "119" ដែលភ្ជាប់ទៅស្ថាប័នពន្លត់អគ្គិភ័យគឺសម្រាប់ប្រើប្រាស់នៅពេលកើតមានអគ្គិភ័យឬការសង្គ្រោះបន្ទាន់។ លេខមួយណាក៏ដោយ ក៏អ្នកមិនត្រូវប្រើប្រាស់ក្រៅពីពេលអាសន្នជាដាច់ខាត។

## នៅពេលទូរសព្ទទៅ **លេខ110** សូមអ្នកប្រាប់អំពីព័ត៌មាន **ដូចតទៅ** ៖

1. តើមានអ្វីកើតឡើង? (ចោរកម្មឬគ្រោះថ្នាក់ចរាចរណ៍ជាដើម ដោយសូមប្រាប់លម្អិតតាមដែលអាចធ្វើបានអំពីអ្វីដែលបានកើតឡើង)
2. តើហេតុការណ៍កើតឡើងនៅពេលណា និង នៅកន្លែងណា?
3. អំពីជនល្មើស (ជាមនុស្សដូចម្តេច អាយុប្រហែលប៉ុន្មាន សម្លៀកបំពាក់ ជាដើម ដោយសូមប្រាប់ទៅតាមអ្វីដែលអ្នកដឹង)
4. តើជនល្មើសបានរត់គេចទៅទិសដៅណា? (សូមប្រាប់អំពីឈ្មោះផ្លូវឬសញ្ញាសម្គាល់ជាដើម)
5. ឈ្មោះ អាសយដ្ឋាន និង លេខទូរសព្ទរបស់អ្នក

បើអ្នកទូរសព្ទទៅលេខ110 ដើម្បីពិគ្រោះអំពីបញ្ហាដែលមិនចាំបាច់ត្រូវឆ្លើយតបជាបន្ទាន់ នោះអាចបង្កភាពយឺតយ៉ាវដល់ការឆ្លើយតបចំពោះហេតុការណ៍អាសន្នឬគ្រោះថ្នាក់នានា។ ករណីអ្នកមានកង្វល់ឬក្តីបារម្ភជាដើម សូមប្រើប្រាស់លេខទូរសព្ទសម្រាប់ការពិគ្រោះជាមួយនឹងប៉ូលិស(#9110)។

出典元：広報けいしちょう第 98 号より抜粋し、JITCO が作成

## ទូរសព្ទទៅ **លេខ119** គឺនៅពេលមាន **អគ្គិភ័យ** និង **ការសង្គ្រោះបន្ទាន់**

### —ករណីជាអគ្គិភ័យ—

| 消防署 | あなた |
|---|---|
| 消防です。火事ですか、救急ですか。 | 火事です。 |
| 住所はどこですか？ | ●●市（●●区）●●町●丁目●番地です。<br>◀សូមប្រាប់អំពីអាសយដ្ឋាននៃទីកន្លែងដែលជាប្រភពអគ្គិភ័យ។ បើអ្នកមិនដឹង សូមប្រាប់អំពីឈ្មោះរបស់អគារឬផ្លូវប្រសព្វសម្រាប់ជាសញ្ញាសម្គាល់។ |
| 何が燃えていますか？ | ●●が燃えています。<br>◀សូមប្រាប់អំពីទីកន្លែងនិងវត្ថុដែលកំពុងឆាបឆេះ។ |
| 燃え方やけが人は？ | 例：けが人が一人います。　逃げ遅れている人がいます。　天井に火が届いています。<br>◀សូមប្រាប់អំពីស្ថានភាពនៃអគ្គិភ័យ។ |

### —ករណីជាការសង្គ្រោះបន្ទាន់—

| 消防署 | あなた |
|---|---|
| 消防です。火事ですか、救急ですか。 | 救急です。 |
| 住所はどこですか？ | ●●市（●●区）●●町●丁目●番地です。<br>◀សូមប្រាប់អំពីអាសយដ្ឋាននៃទីកន្លែងដែលអ្នកកំពុងស្ថិតនៅ។ បើអ្នកមិនដឹង សូមប្រាប់អំពីឈ្មោះរបស់អគារឬផ្លូវប្រសព្វសម្រាប់ជាសញ្ញាសម្គាល់។ |
| どうしましたか？ | 例：胸が痛いです。<br>同僚が倒れて意識がありません。<br>◀សូមប្រាប់អំពីថាតើនរណា កើតមានអាការៈដូចម្តេច ហើយចាប់តាំងពីពេលណា។ |
| あなたの名前と連絡先を教えてください。 | ●●です。電話番号は●●●●●です。<br>◀បុគ្គលិកស្ថានីយពន្លត់អគ្គិភ័យអាចនឹងសាកសួរអ្នកអំពីពាក្យសញ្ញាលម្អិតបន្ថែមទៀត។ សូមអ្នកប្រាប់នូវព័ត៌មានដែលអ្នកអាចឆ្លើយបាន។ |

＊នេះគឺជាឧទាហរណ៍នៃការសាកសួរជាលក្ខណៈទូទៅ។

ករណីកើតមានរបួសឬជំងឺភ្លាមៗ ហើយអ្នកពិបាកសម្រេចចិត្តថាតើគួរហៅរថយន្តសង្គ្រោះ ឬ គួរទៅមន្ទីរពេទ្យភ្លាមៗពេលនោះ សូមអ្នកប្រើប្រាស់សេវាពិគ្រោះតាមទូរសព្ទអំពីការសង្គ្រោះបន្ទាន់ ដែលមានលេខ (#7119)។

出典元：（一財）日本防火・防災協会HP、総務省消防庁HP（https://www.fdma.go.jp/publication/portal/post1.html）より抜粋し、JITCOが作成

នៅJITCO មានលក់សៀវភៅ«សេចក្តីណែនាំពីការរស់នៅប្រទេសជប៉ុន» ជា13ភាសា ដើម្បីណែនាំដល់ជនបរទេសដែលស្នាក់នៅប្រទេសជប៉ុន ។ អ្នកក៏អាចសាកអាន នៅ ហាងអនឡាញលក់ឯកសារសិក្សា របស់JITCO តាមអ៊ីនធឺណិតផងដែរ សូមកុំភ្លេចចូលមើលគេហទំព័រទាំងអស់គ្នា។

## នៅរថភ្លើង ឬ រថយន្តក្រុង ជាដើម



# យើងនាំគ្នាពិនិត្យមើលសុជីវធម៌ នៅពេលប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ

- នៅក្នុងរថភ្លើងឬរថយន្តក្រុង យើងមិនត្រូវនិយាយសម្លេងខ្លាំងៗនោះទេ។ម្យ៉ាងទៀត ការនិយាយឆ្លងឆ្លើយតាមទូរសព្ទជាដើម គឺត្រូវបានហាមឃាត់។ ហើយសូមអ្នកប្រុងប្រយ័ត្នចំពោះការលេចឮសម្លេងចេញពីកាសត្រចៀកផងដែរ។



- នៅពេលមានអ្នកធ្វើដំណើរផ្សេងទៀត យើងត្រូវតម្រង់ជួរ។ អ្នកមិនត្រូវប្រជ្រៀតចូលកាត់ជួរនោះទេ ដោយត្រូវបើកផ្លូវនៅជុំវិញទ្វារឱ្យបានធំទូលាយ ហើយរង់ចាំដល់មនុស្សចុះពីរថភ្លើងអស់ (ជាទូទៅនៅប្រទេសជប៉ុនគឺផ្តល់អាទិភាពដល់អ្នកដែលត្រូវចុះពីរថភ្លើង)។



- នៅក្នុងទូរថភ្លើងដែលកកកុញ បើអ្នកកំពុងកាន់កាបូបធំដូចជាកាបូបស្ពាយក្រោយជាដើម សូមអ្នកកាន់ដោយទម្លាក់ដៃចុះ ឬក៏ ប្រើកន្លែងទុកឥវ៉ាន់ដែលស្ថិតនៅលើកៅអីអង្គុយជាដើម ដើម្បីចៀសវាងបង្កការរំខានដល់មនុស្សជុំវិញ។



- ក្រៅពីរថភ្លើងល្បឿនលឿននិងរថយន្តក្រុងផ្លូវឆ្ងាយជាដើម នៅក្នុងរថភ្លើងធម្មតាឬរថយន្តក្រុងតាមចំណត ជាគោលការណ៍គឺហាមឃាត់មិនឱ្យបរិភោគអាហារឬភេសជ្ជៈទេ។ បើអ្នកត្រូវពិសាភេសជ្ជៈដើម្បីបំពេញជាតិទឹកជាដើមដោយចៀសពុំរួច សូមអ្នកប្រុងប្រយ័ត្នកុំឱ្យកំពប់។





នៅក្នុងរថភ្លើងឬរថយន្តក្រុងជាដើមគឺមាន "កៅអីអាទិភាព" ដែលបង្ហាញរូបសញ្ញាដូចនេះ។ "កៅអីអាទិភាព" គឺជាកៅអីដែលសូមឱ្យអ្នកផ្តល់អាទិភាពអង្គុយចំពោះមនុស្សចាស់ ជនពិការកាយសម្បទា ស្ត្រីមានផ្ទៃពោះ ឬ អ្នកដែលមានកូនតូចមកជាមួយ។ នៅពេលរថភ្លើងមិនកកកុញ នរណាក៏អាចអង្គុយនៅទីនោះបានដែរ ប៉ុន្តែ បើមានមនុស្សដែលត្រូវផ្តល់អាទិភាពចូលមកក្នុងរថភ្លើង សូមអ្នកនិយាយទៅកាន់គាត់ ហើយផ្តល់កន្លែងអង្គុយនោះសម្រាប់គាត់។


**とも**

2026年1月 冬季号

2026年1月1日発行

発　行　公益財団法人 国際人材協力機構（JITCO）
総務部広報室
〒108-0023
東京都港区芝浦2-11-5
五十嵐ビルディング

電　話　03-4306-1166（ダイヤルイン）

JITCO ホームページ　https://www.jitco.or.jp/

jitco.official

@jitco_official